# Living the Lotus

## Buddhism in Everyday Life

11
2024
VOL. 230




## Rissho Kosei-kai of San Francisco Celebrated Its 45th Anniversary on September 15



















Living the Lotus
Vol. 230 (November 2024)

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin

*Living the Lotus* is published monthly
By Rissho Kosei-kai International,
Fumon Media Center, 2-7-1 Wada,
Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp

រីហ្សូកូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើន មានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូកូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូកូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

*President's Message*

# ជំនួបដែលចិញ្ចឹមចិត្ត គោរពនិងភាពខ្មាសអៀន ①

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## អភិវឌ្ឍចិត្តគោរព

កាលពីឆ្នាំមុននៅម្តុំៗខែនេះ ខ្ញុំព្រះករុណាអាត្មាភាពបានលើកយកពាក្យរបស់ព្រះគ្រូយ៉ាស៊ឺអូកាម៉ាសាហៀរ៉ូ ( Yasuoka Masahiro) ដែលចែងថា "អ្វីដែលសំខាន់បំផុតសម្រាប់ការរីកចម្រើនរបស់មនុស្សគឺការអភិវឌ្ឍចិត្តគោរពនិងភាពអៀនខ្មាស"ហើយបានបង្ហាញនូវមុខសញ្ញាជាគោលដៅសម្រាប់សមាគមយើងនៅឆ្នាំនេះផងដែរ ។បំណងប៉ងប្រាថ្នាចង់ចូលទៅជិតអ្វីដែលអស្ចារ្យមានសារៈសំខាន់មិនត្រឹមតែសម្រាប់មនុស្សដែលមានជំនឿទៅលើសាសនាណាមួយតែប៉ុណ្ណោះទេ ប៉ុន្តែគឺសម្រាប់មនុស្សទាំងអស់ជាទូទៅ ហើយការគោរពគ្នាទៅវិញទៅមករវាងមនុស្សនិងមនុស្សគឺជាមូលដ្ឋានគ្រឹះសម្រាប់បង្កើតសន្តិភាពសង្គម។

ទោះជាយ៉ាងណាក៏ដោយ ដូចដែលខ្ញុំព្រះករុ ណាអាត្មាភាពធ្លាប់បាននិយាយច្រើនដងមកហើយថា អ្នកដែលមិនអាចគោរពខ្លួនឯង មិនអាចគោរពអ្នកដទៃបានទេ។ នៅពេលដែលគេសួរថាតើខ្ញុំព្រះករុណាអាត្មាភាពអាចគោរពខ្លួនឯងបានទេ ? និយាយដោយស្មោះត្រង់ទៅខ្ញុំព្រះករុណាអាត្មាភាពច្បាស់ជានឹងឆ្លើយថាវាជាការពិបាកណាស់មិនខានឡើយ។

តែទោះបីជាដូច្នេះក៏ដោយ ដូចដែលខ្ញុំព្រះករុ ណាអាត្មាភាពបាននិយាយច្រើនដងរួចមកហើយថាដោយសារតែគុណបុណ្យដែលបានឃើញព្រះគ្រូកៃស្វសាម៉ាដែលលោកសំពះហើយសំពះទៀតដោយផ្តុំបាតដៃស្តាំដែលតំណាងឱ្យភពឯនាយខាងនោះនិងបាតដៃឆ្វេងដែលតំណាងឱ្យភពបច្ចុប្បន្នជាប់គ្នាជានិច្ចជាកាល ខ្ញុំព្រះករុណាអាត្មាភាពក៏បានចាប់ភ្លឹកពីគុណតម្លៃរបស់ខ្លួនឯង។ និយាយទៅដូចជាគួរឱ្យខ្មាសអៀនដែរ គឺថារាល់ពេលដែលខ្ញុំព្រះករុណាអាត្មាភាពលើកដៃប្រណម្យទៅរូបព្រះពុទ្ធនិងអ្នកដែលចែកស្ថានទៅព្រឹកល្ងាច ខ្ញុំព្រះករុណាអាត្មាភាពមានអារម្មណ៍ថា "ព្រះពុទ្ធនិងអ្នកដែលចែកស្ថានទៅក៏សំពះមកខ្ញុំព្រះករុណាអាត្មាភាពវិញដែរ"។

ដើមឆ្នាំនេះនៅថ្ងៃដែលសរសេរអក្សរជក់ជាដំបូងខ្ញុំព្រះករុណាអាត្មាភាពបានសរសេរពាក្យថា "គោរពកោតខ្លាច" ។ ជាការពិតណាស់នេះគឺដោយសារតែខ្ញុំព្រះករុណាអា ត្មាភាពផ្តោតសំខាន់ទៅលើចិត្តគោរពនោះឯង។ ទោះជាយ៉ាងណាក៏ដោយពាក្យថា "គោ រពកោតខ្លាច" គេប្រើនៅពេលដែលគេគិតពីភាពអស្ចារ្យនៃព្រះអាទិទេពឬព្រះពុទ្ធ ឬចក្រ វាលឬមហាធម្មជាតិដែលជាអំណាចនៃអត្ថិ ភាពដែលនៅខ្ពស់ឆ្ងាយសែនឆ្ងាយពីចំណេះដឹងនិងសមត្ថភាពរបស់មនុស្ស ។ គេក៏អាចរាប់បញ្ចូលបានទាំងការគោរពចំពោះព្រះសង្ឃឬអ្នកប្រាជ្ញដែលមានឈ្មោះចារក្នុងប្រវត្តិសា

ស្រ្តនិងឥស្សរជនដ៏អស្ចារ្យបានដែរ ក៏ប៉ុន្តែក្រៅពីនេះ ខ្ញុំព្រះករុណាអាត្មាភាពក៏មានសេចក្តីគោរពយ៉ាងជ្រាលជ្រៅចំពោះ "ជំនួប" នីមួយៗជាមួយនឹងមនុស្សនិងអ្វីៗដែលខ្ញុំព្រះករុណាអាត្មាភាពមានទំនាក់ទំនងជាមួយជារៀងរាល់ថ្ងៃ ថាជាវត្ថុដ៏គួរឱ្យស្ញប់ស្ញែង ហើយខ្ញុំព្រះករុណាអាត្មាភាពជឿ ថាចិត្តគោរពក៏អាចលូតលាស់នៅក្នុងជីវភា ពប្រចាំថ្ងៃបានដែរ។

## ការជួបគ្នាគឺជាជីវជាតិសម្រាប់ព្រលឹង

យើងលើកឧទាហរណ៍ករណីឪពុកម្តាយនិងកូន។ ប្រហែលជាដោយសារតែឃើញឪពុកម្តាយដែលតែងតែគិតថាទស្សនៈរបស់គាត់ឯណុះទើបត្រឹមត្រូវហើយមើលទៅបានជាគាត់តែងតែជេរស្តីឬខឹងកូន ល្មមតែទស្សនវិទូចិនម៉ៅស៊ីនិយាយថា "មហាបុរសមិនបង្រៀនកូនរបស់គាត់ទេ"។ តាំងពីដើមរៀងមកគេតែងតែនិយាយថា ជាការពិបាកណា ស់ក្នុងការបង្កើតស្មារតីនៃការគោរពរវាងឪពុកម្តាយនិងកូន។ ខ្ញុំព្រះករុណាអាត្មាភាពជឿថាទាំងឪពុកម្តាយនិងទាំងកូនអ្នកទាំងសងខាងសុទ្ធតែមានបុគ្គលិកលក្ខណៈផ្ទាល់ខ្លួនរបស់ពួកគេដែលខុសពីគ្នាទៅវិញទៅមក។ ប្រសិនបើទាំងសងខាង អាចមានអារម្ម ណ៍បែបនេះ ឪពុកម្តាយគួរតែគោរពបុគ្គលិកលក្ខណៈរបស់កូនដែរទើបបាន។ហើយឪពុកម្តាយមិនត្រូវធ្វើអ្វីដែលផ្ទុយពីអ្វីដែលខ្លួននិយាយឡើយ។ពោលគឺថាពុតគ្រូនិងច្បាប់គ្រូត្រូវតែដូចគ្នា។ខ្ញុំព្រះករុណាអាត្មាភាពយល់ថានេះគឺជាការបណ្តុះនិងចិញ្ចឹមសេចក្តីគោរពនៅក្នុងចិត្តរបស់ឪពុកម្តាយនិងកូន។

បើនិយាយពីសេចក្តីគោរព យើងតែងតែផ្តោតទៅលើតែអ្នកដែលនៅពីលើខ្ពស់ពីលើយើងប៉ុណ្ណោះ។ ក៏ប៉ុន្តែមនុស្សដែលមានកម្រិតដូចគ្នានឹងយើង ឬអ្នកដែលក្មេងជាង និងមានបទពិសោធន៍តិចជាងយើងក៏ជាមនុស្សសំខាន់ដែលអាចជួយយើងឱ្យអភិ វឌ្ឍចិត្តគោរពបានដែរ។ ចំពោះទំនាក់ទំនងរវាងគូស្នេហា និងមិត្តភក្តិក៏ដូចគ្នាដែរ។

ចំណុចសំខាន់គឺត្រូវទទួលស្គាល់បុគ្គលិកលក្ខណៈរបស់អ្នកដទៃ ដូចជាមានចិត្តរំភើបហើយសរសើរនិងរៀនសូត្រពីគុណសម្បត្តិ និងគុណធម៌របស់អ្នកដទៃ ទាំងនេះហើយដែលជំរុញឱ្យស្មារតីគោរពខ្លួនឯងនិងអ្នកដទៃលូតលាស់។ បើយើងទទួលស្គាល់វិធីនេះ រាល់ការជួបជាមួយមនុស្សគឺជាជីវជាតិសម្រាប់ចិញ្ចឹមនិងបណ្តុះស្មារតីគោរពឱ្យលូតលាស់ធំធាត់ ហើយខ្ញុំព្រះករុណាអាត្មាភាពជឿថា ទង្វើនេះមិនខុសពីកិច្ចប្រតិបត្តិការគោរពអ្នកដទៃរបស់ព្រះពោធិសត្វសទបរិភូតៈឡើយ។

លោកម៉ាតស៊ឺស៊ីតា ខូណូស៊ឺគេ(Konosuke Matsushita) ដែលគេស្គាល់ថាជាបិតានៃការគ្រប់គ្រង បាននិយាយថា "នៅលើមេឃ លើដី និងធម្មជាតិ, លើលោកយើងនេះ ប្រសិនបើអ្នកមានបេះដូងនៃការគោរពនោះមានរបស់រាប់មិនអស់ដែលគួរឱ្យគោរព"(ដកស្រង់ចេញពីសៀវភៅ" បើកផ្លូវ" / បោះពុម្ពផ្សាយដោយវិទ្យាស្ថាន PHP) ។ លើសពីនេះទៅទៀតលោកបាននិយាយថា "មនុស្សត្រូវបានផ្តល់ឱ្យនូវសមត្ថភាពក្នុងការស្វែងរកតម្លៃដែលសមនឹងទទួលបានការគោរពនៅក្នុងវត្ថុនិងនៅក្នុងមនុស្ស " (ដូចខាងលើ) ហើយលោកបានអំពាវនាវឱ្យយើងប្រើប្រា ស់សមត្ថភាពនោះ ហើយនិងបង្កើនការគោរពគ្នាទៅវិញទៅមក។

ទោះជាយ៉ាងណាក៏ដោយព្រះគ្រូយ៉ាស៊ឺអូកាម៉ាសាហៀរ៉ូ ( Rev. Masahiro Yasuoka )ក៏បា នបង្រៀនយើងដែរថា "នៅពេលដែលបេះ ដូងនៃការគោរពនេះរីកចម្រើនឡើងសេចក្តីខ្មាសអៀនក៏កើតមានឡើងដែរដោយសារតែយើងធ្វើស្វ័យត្រិះរិះឆ្លុះបញ្ចាំងពីការពិតនៃភាពតូចទាបរបស់ខ្លួនយើង" ( Rev. Masa hiro Yasuoka ) ។ ពោលគឺថាការជួបជាមួយមនុស្សដទៃក៏ជំរុញឱ្យមានអារម្មណ៍សំខាន់មួយទៀតដែរគឺភាពអៀនខ្មាស។ ខែក្រោយបន្ថែមពីលើភាពខ្មាសអៀននេះ ខ្ញុំព្រះករុ ណាអាត្មាភាពនឹងលើកយកជំនួបមួយដែលមានសារៈសំខាន់សម្រាប់យើងទាំងអស់គ្នាគឺអត្ថន័យនៃជំនួបដែលឆ្លងកាត់តាមការផ្សព្វផ្សាយព្រះពុទ្ធសាសនាមកគិតជាមួយគ្នា។



『កូសេ』លេខខែ វិច្ឆិកា ឆ្នាំ ២០២៤

# Rissho Kosei-kai International

## Make Every Encounter Matter




## A Global Buddhist Movement




**Information about local Dharma centers**

facebook

X

We welcome comments on our newsletter Living the Lotus: [living.the.lotus.rk-international@kosei-kai.or.jp](mailto:living.the.lotus.rk-international@kosei-kai.or.jp)